សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ តើចាត់ព្រះពុទ្ធជាទស្សនវិទូត្រឹមត្រូវឬទេ?

www.hoksavann.org

ថ្ងៃទី១ មីនា ២០១៣



ការបញ្ចូលព្រះពុទ្ធជាទស្សនវិទូ (Philosophe) ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គជាទស្សនវិជ្ជា (Philosophy) ក្នុងចំណោមទស្សនវិទូទាំងឡាយក្នុងលោកពុំត្រឹមត្រូវឡើយ ព្រោះព្រះពុទ្ធត្រាស់ដឹង (Enlightenment) នូវ**អរិយសច្ច** (Noble Truth) ជាធម៌ពិត សំរាប់រំដោះមនុស្សសត្វដែលប្រតិបត្តិតាមឲ្យរួចចាកទុក្ខ ហើយព្រះអង្គមានព្រះទ័យបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង ហើយមានលក្ខណៈផ្ទុយអំពីការរកឃើញធម្មតារបស់ទស្សនវិទូទាំងឡាយក្នុងលោក ។ ពាក្យថា ទស្សនវិជ្ជាដែលកើតពីការរកឃើញឬការយល់ឃើញរបស់ទស្សនវិទូទាំងនោះ មានពីរបទគឺ **ទស្សនៈ**១បទ និង**វិជ្ជា**១បទ ប្រែថា**វិជ្ជាអំពីទស្សនៈ** (Point of View) គឺជាវិជ្ជាសិក្សាអំពីទស្សនៈឬមតិយោបល់ផ្សេងៗ របស់អ្នកប្រាជ្ញទាំងឡាយ ជាទស្សនវិទូក្នុងលោក ។ ពាក្យថា **ទស្សនវិជ្ជា**នេះ គេឲ្យអត្ថន័យម៉្យាងទៀតថា ការស្រឡាញ់គតិបណ្ឌិត (Love of Wisdom) ។ ទស្សនៈនេះមានបទវិគ្គហៈថា **ទិដ្ឋន្តិ ទស្សនំ** ប្រែថា **ទស្សនៈ** គឺទិដ្ឋិនេះឯង ។ ក្នុងបាលីព្រះពុទ្ធសាសនា បើឃើញពាក្យថា **ទិដ្ឋិ** បានដល់ **មិច្ឆាទិដ្ឋិ** ដូចធម៌នៅក្នុងអាសវៈ៤យ៉ាងគឺ **ទិដ្ឋសវៈ** ប្រែថា អាសវៈ គ្រឿងដេកត្រាំ គឺទិដ្ឋិការយល់ខុស ។ ដូច្នេះ ទស្សនវិជ្ជាដែលកើតអំពីគំនិតទស្សនវិទូនោះ នៅមានគំនិតយល់ខុស ពុំអាចប្រៀបធៀបការត្រាស់ដឹងរបស់ព្រះពុទ្ធបានឡើយ ។ ពាក្យថា **សម្មាទិដ្ឋិ** ប្រែថា ការយល់ត្រូវ (Right Understanding) ដោយបន្ថែមសម្មានៅខាងដើមទិដ្ឋិ ។ ទស្សនវិជ្ជាគឺជាការបញ្ចេញមតិយោបល់របស់មនុស្សបុថុជ្ជន ដែលហៅថាទស្សនវិទូ ដោយពុំបានអប់រំចិត្តឲ្យបានបរិសុទ្ធដូចព្រះពុទ្ធជាម្ចាស់ឡើយ ។ មូលដ្ឋាននៃទស្សនវិជ្ជា គឺសិក្សាពីសង្គមវិទ្យា (Sociology) ចិត្តវិទ្យា (Psychology) និងតក្កវិទ្យា (Logic) ។ ទស្សនវិទូសម័យបូរាណនៅក្រិក ដូចលោក**ប្លាតុង** លោក**សូក្រាត** លោក**អារីស្តូត** នៅសម័យកណ្តាលនាប្រទេសបារាំង ដូចលោក**ដេកាត** លោក**ពីតាហ្គ័រ** នៅអាល្លឺម៉ង់ដូចលោក Hengel លោក Openhaver លោក Karl Max ជាដើម ។ អស់លោកទាំងនោះ លោកខ្លះមានគំនិតជាទេវនិយម ខ្លះជាសម្ភារៈនិយម គ្រាន់តែបញ្ចេញជាទ្រឹស្តីតាមការយល់ឃើញរបស់ខ្លួន ដោយពុំបានអប់រំកាយវាចាចិត្តឲ្យបានបរិសុទ្ធឡើយ ។ មានទស្សនវិទូខ្លះដូចលោក Karl Max មេបង្កើតទ្រឹស្តីកុម្មុយនិស្ត បានបញ្ចេញទស្សនៈធ្វើឲ្យពិភពលោកមានទំនាស់គ្នា បង្កើតជាសង្គ្រាមបង្ហូរឈាមគ្នា ស្លាប់មនុស្សរាប់រយលាននាក់ ដោយសារទស្សនវិទូមិច្ឆាទិដ្ឋិនេះឯង ។ ចំណែកព្រះពុទ្ធជាម្ចាស់វិញ ព្រះអង្គបានអប់រំព្រះទ័យព្រះអង្គដល់នូវភាពបរិសុទ្ធ ទើបប្រៀនប្រដៅមនុស្សសត្វជាក្រោយ មានប្រៀនប្រដៅមិនឲ្យធ្វើបាបបៀតបៀនគ្នាជាដើម ។ ដូចនេះបញ្ជាក់ថា ទស្សនវិទូទាំងនោះពុំអាចយកមកប្រៀបធៀបនឹង **ព្រះពុទ្ធជាម្ចាស់** ដែលជាបុគ្គលបរិសុទ្ធបានឡើយ ទាំងព្រះធម៌ដែលព្រះអង្គសំដែងក៏ជាព្រះធម៌បរិសុទ្ធ ពុំមែនជាធម៌ធ្វើឲ្យអ្នកប្រព្រឹត្តតាមមានទុក្ខបង្កសេចក្តីទុក្ខសោកដល់សង្គមមនុស្ស ដូចជាទស្សនវិទូខ្លះឡើយ ។

ការត្រាស់ដឹងធម៌របស់ព្រះពុទ្ធនិងការរកឃើញរបស់ទស្សនវិទូនូវអ្វីមួយមានលក្ខណៈខុសគ្នា គឺទស្សនវិទូក្នុងលោកបានដឹងបានយល់អ្វីមួយ កើតឡើងដោយការពិសោធន៍ធម្មតា តាមវិញ្ញាណទាំង៥គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ មិនមានបញ្ញាជាន់ខ្ពស់ផ្នែកលោកុត្តរបញ្ញាដឹងរឿងពិតឡើយ ។ ចំណែកព្រះពុទ្ធព្រះបរមគ្រូវិញ បានទទួលអារម្មណ៍តាមអាយតនៈនោះដែរ ប៉ុន្តែមានញាណមួយសំរាប់ដឹងរឿងពិត គឺវិបស្សនាញាណ ទុកដូចជាអតិសុខុមទស្សន៍ (Microscope) ជាប្រដាប់មួយបែបដែលក្រុមវិទ្យាសាស្ត្រយកទៅឆ្លុះមើលរបស់ដែលល្អិតបំផុតដែលមើលនឹងភ្នែកធម្មតាពុំឃើញ ។ គឺព្រះអង្គមានញាណទស្សនៈដែលចែកជាពីរបទគឺ **ញាណ** និង **ទស្សនៈ** ។ ទស្សនៈ គឺការដឹងតាមវិញ្ញាណទាំង៥ ឯញាណ គឺប្រាជ្ញាដឹងរឿងពិត ឧទាហរណ៍ដូចការឃើញរូបដែលមនុស្សធម្មតាឃើញរូបថាល្អ ថាស្អាត ដូចជារូបមនុស្ស ប៉ុន្តែបើលើកយកអាការៈ៣២មានសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម មកពិនិត្យពិចារណាតាមញាណនិងទស្សនៈ ឃើញពុំស្អាត ពុំល្អឡើយ គឺចេញផុតអំពីជំនឿដែលពឹងផ្អែកតែទៅលើអាយតនៈទាំង៥គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។ ដូច្នេះព្រះពុទ្ធគេពុំអាចហៅព្រះអង្គថាទស្សនវិទូបានឡើយ ព្រោះព្រះអង្គជាអ្នកត្រាស់ដឹងដោយប្រពៃ គឺ **សម្មាសម្ពុទ្ធោ** ។ ព្រះអង្គមានព្រះនាមថា **ពុទ្ធោ** ប្រែថាការភ្ញាក់រលឹកអំពីអវិជ្ជា ហើយត្រាស់ដឹងនូវអរិយសច្ច៤ (Four Noble Truth) ។ ព្រះនាម **អរហំ** ប្រែថា ការឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសជាដើម ។ ក្នុងន័យនេះ គេមិនត្រូវបញ្ចូលព្រះពុទ្ធឲ្យនៅក្នុងចំណោមទស្សនវិទូទាំងនោះទេ **ព្រោះព្រះពុទ្ធជាអរិយបុគ្គល** ចំណែកទស្សនវិទូទាំងនោះ ជាបុថុជ្ជនបុគ្គល ។ មួយទៀត បើគេបន្ថែមពាក្យឲ្យខ្ពស់ជាងនេះថា ព្រះពុទ្ធ **អភិទស្សនវិទូ** ក៏រឹតតែមិនបានទៅទៀត ព្រោះថា អភិ ប្រែថា ក្រៃលែង គឺព្រះពុទ្ធជាទស្សនវិទូដ៏ក្រៃលែង មានន័យថា ព្រះពុទ្ធជាទស្សនវិទូយល់ខុសក្រៃលែងជាងទស្សនវិទូដែលយល់ខុសដទៃទៀត ។ ប៉ុន្តែគេអាចប្រើពាក្យ **ព្រះពុទ្ធជាញាណទស្សនវិទូ** គឺត្រូវបញ្ចូលពាក្យថា **ញាណ** ដែលជាតួបញ្ញាមួយទៀតនៅខាងដើមពាក្យ **ទស្សនវិទូ** ដែលប្រែថា ព្រះពុទ្ធជ្រាបនូវលោកដោយញាណនិងទស្សនៈ ទើបត្រឹមត្រូវ ព្រោះមានញាណជាតួបញ្ញានៅក្នុងនោះ ។ ក្រៅពីញាណទស្សនវិទូនៅក្នុងពុទ្ធគុណ គេហៅព្រះអង្គថា លោកវិទូ ដែលប្រែថា អ្នកត្រាស់ដឹងនូវលោក គឺត្រាស់ដឹងសត្វលោក របស់មានវិញ្ញាណ សង្ខារលោក របស់គ្មានវិញ្ញាណ និងឱកាសលោក របនាសម្ព័ន្ធទំនាក់ទំនងគ្នា ។ ការពិត ការត្រាស់ដឹងរបស់ព្រះពុទ្ធ និងការរកឃើញរបស់ទស្សនវិទូ ឬ

*អ្នកវិទ្យាសាស្ត្រមានលក្ខណៈផ្សេងគ្នា គឺការត្រាស់ដឹងរបស់ព្រះពុទ្ធកើតឡើងពីការពិសោធន៍ផ្លូវចិត្ត តាមមគ្គប្រកបដោយអង្គ៨ រួមឲ្យខ្ញីបានដល់* ***សីល សមាធិ បញ្ញា*** *ទើបជ្រាបការពិតនូវសង្ខារមានខន្ធ៥ជាដើម ដែលប្រព្រឹត្តទៅជា* ***អនិច្ចំ ទុក្ខំ*** *និង* ***អនត្តា*** *។ ដោយព្រះអង្គមានញាណនិងទស្សនៈជ្រាបរឿងពិតនេះហើយ ទើបធ្វើឲ្យ* ***អវិជ្ជា តណ្ហា ឧបាទាន*** *និង* ***កម្ម*** *នៃព្រះអង្គអស់ទៅ សេចក្ដីទុក្ខមានជាតិទុក្ខជាដើមក៏ត្រូវរលត់ ។ ទស្សនវិទូនិងអ្នកវិទ្យាសាស្ត្របានស្រាវជ្រាវរកការពិត ដោយពឹងផ្អែកទៅលើអាយតនៈនិងឧបករណ៍ជាសម្ភារៈ សំរាប់ធ្វើការពិសោធន៍អាចរកឃើញការពិតខ្លះ ជាលោកិយសច្ចៈសំរាប់សម្រួលការរស់នៅរបស់សង្គមមនុស្សឲ្យបានសុខស្រួល ប៉ុន្តែអ្នកទស្សនវិទូនិងអ្នកវិទ្យាសាស្ត្រមួយប្រភេទទៀតរកឃើញនិងផលិតសម្ភារៈសម្លាប់មនុស្ស ដូចជាគ្រឿងសាស្ត្រាវុធ គ្រាប់បែកបរមាណូប្រល័យលោកជាដើម ចំណែកព្រះពុទ្ធរកឃើញនិងសំដែងព្រះធម៌ ដើម្បីរំលត់ទុក្ខរបស់មនុស្សសត្វតែម៉្យាងប៉ុណ្ណោះ ។*

* *

*